## ថ្នាំបង្ការកូវីដ-១៩

# សំណួររបស់អ្នកត្រូវបានឆ្លើយ




## ហេតុអ្វីបានជាខ្ញុំត្រូវការចាក់ថ្នាំបង្ការ?

អ្នកណាក៏ដោយក្នុងវ័យណាក៏ដោយ អាចមានជំងឺកូវីដ-១៩។ ប្រសិនបើអ្នកពុំមានចាក់ថ្នាំបង្ការទេ អ្នកមានហានិភ័យខ្ពស់ជាងគេក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ពីវីរុសនោះ។ ដោយការចាក់ថ្នាំបង្ការ អ្នកនឹងអាចធ្វើដំណើរទៅទីនានា ទៅចូលរួមក្នុងពិធីផ្សេងៗ ហើយនិងជួបជនជាទីស្រឡាញ់របស់អ្នកក្នុងអនាគត។

## ហេតុអ្វីបានជាខ្ញុំត្រូវការចាក់ថ្នាំបង្ការបន្ថែមកម្លាំងការពារ (booster vaccination)?

ថ្នាំបង្ការពីរដូសផ្តល់ការការពារល្អណាស់ ជាពិសេស ប្រឆាំងនិងជំងឺធ្ងន់ធ្ងរ។ ដូសបន្ថែមកម្លាំងការពារ គឺធានាឲ្យការការពារដែលផ្តល់ដោយដូសទាំងពីរដំបូងគេនោះ មានភាពកាន់តែមាំ ហើយនិងមានប្រសិទ្ធភាព កាន់តែយូរ។ វាជាវិធីប្រសើរជាងគេក្នុងការរក្សាឲ្យអ្នក ជនជាទីស្រឡាញ់របស់អ្នក ហើយនិងសហគមន៍ យើងមានសុវត្ថិភាព។

## តើថ្នាំបង្ការនោះមានសុវត្ថិភាពឬទេ?

ថ្នាំបង្ការនោះមានសុវត្ថិភាព ហើយជួយស្រោចស្រង់ជីវិតប្រជាពលរដ្ឋ។ ការិយាល័យ Therapeutic Goods Administration (TGA) មិនអនុម័តឲ្យមានការប្រើថ្នាំបង្ការណាមួយក្នុងប្រទេសអូស្ត្រាលីទេលុះណាតែវាមានសុវត្ថិភាពនិងមានប្រសិទ្ធភាព។

## តើថ្នាំបង្ការនោះមានសុវត្ថិភាពឬទេបើខ្ញុំមានផ្ទៃពោះ ឬក៏បំបៅកូនសព្វថ្ងៃនេះ។

ថ្នាំបង្ការប្រភេទម៉ូឌើណា (Moderna) និង ហ្វៃស៊ើ (Pfizer) គឺមានសុវត្ថិភាពសម្រាប់ស្ត្រីដែលមានផ្ទៃពោះ មានផែនការប្រុងមានផ្ទៃពោះ ឬក៏បំបៅកូនសព្វថ្ងៃនេះ។ ឥឡូវនេះ ទារករាប់ម៉ឺននាក់ប្រកបដោយសុខភាពល្អ បានប្រសូតចេញពីស្ត្រីដែលមានចាក់ថ្នាំបង្ការហើយ។



Government of South Australia

គំរោងនេះមានការឧបត្ថមថវិកាពីកម្មវិធី Wellbeing SA COVID-19 Vaccine Uptake Community Grants Program

City of Salisbury

ថ្នាំបង្ការកូវីដ-១៩

# សំណួររបស់អ្នកត្រូវបានឆ្លើយ

## តើថ្នាំបង្ការនោះធ្វើឲ្យអត់មានកូនឬទេ?

មិនទេ។ ថ្នាំបង្ការកូវីដ-១៩ មិនធ្វើឲ្យអត់មានកូនទេ ឬរំងាប់អ្វីៗដែលធ្វើឲ្យយើងមិនអាចមានកូនទេ។

## តើអ្នកណាអាចទទួលថ្នាំបង្ការបាន?

ថ្នាំបង្ការនេះឥតមានគិតថ្លៃទេ ហើយមានសម្រាប់គ្រប់គ្នាចាប់ពីអាយុ៥ឆ្នាំឡើងទៅ។

## តើថ្នាំបង្ការនេះមានសុវត្ថិភាពសម្រាប់កូនខ្ញុំឬទេ?

ថ្នាំបង្ការនេះជាវិធីល្អជាងគេក្នុងការរក្សាកូនរបស់អ្នកកុំឲ្យមានជំងឺកូវីដ-១៩ធ្ងន់ធ្ងរ។

## តើខ្ញុំនៅតែអាចមានជំងឺកូវីដ-១៩ដែរឬទេ បើសិនខ្ញុំបានចាក់ថ្នាំបង្ការហើយ?

ប្រសិនបើអ្នកបានចាក់ថ្នាំបង្ការហើយ អ្នកនៅតែអាចមានជំងឺកូវីដ-១៩ដែរ។ ប៉ុន្តែអ្នកមិនងាយឈឺធ្ងន់ធ្ងរ ឬក៏ត្រូវទៅមន្ទីរពេទ្យទេ។

## តើខ្ញុំអាចទទួលថ្នាំបង្ការថែមកម្លាំងការពារនៅទីណា?

គ្រាន់តែចូលទៅ covidvaccine.sa.gov.a□ ហើយចុច “book now”



សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ **covidvaccine.sa.gov.au**

**សូមអរគុណចំពោះការជួយរក្សាក្រុងសលស៍បើរីឲ្យមានសុវត្ថិភាព។**

Government of South Australia

គំរោងនេះមានការឧបត្ថមថវិកាពីកម្មវិធី Wellbeing SA COVID-19 Vaccine Uptake Community Grants Program

City of Salisbury